# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០១ សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការ និងអនុគណៈកម្មការ ផលិតភាពយន្តភាគរឿង “ កូនប្រុសក្រោមពន្លឺព្រះចន្ទពេញបូណ៌មី ”

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ១.**

បង្កើតគណៈកម្មការផលិតភាពយន្តភាគរឿង **“កូនប្រុសក្រោមពន្លឺព្រះចន្ទពេញបូណ៌មី”** ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ម៉ៅ អាយុទ្ធ** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ជាប្រធាន |
| ២-លោក | **ហ៊ុយ វាសនា** | អ្នកនិពន្ធ និងដឹកនាំរឿង | ជាអនុប្រធាន |
| ៣-ឯ.ឧ.នាយឧ. | **ណឹម សុវត្ថិ** | ទីប្រឹក្សារាជរដ្ឋាភិបាល | ជាទីប្រឹក្សា |
| ៤-ឯ.ឧ.នាយឧ. | **សៅ សុខា** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ជាទីប្រឹក្សា |
| ៥-ឯ.ឧ.នាយឧ. | **ហ៊ីង ប៊ុនហៀង** | នាយករងខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី | ជាទីប្រឹក្សា |
| ៦-ឧ.ឯក | **ជឿន សុវណ្ណថា** | មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី២ | ជាទីប្រឹក្សា |
| ៧-ឯកឧត្តម | **ថាន់ ឆារស័ជួន** | ជំនួយការសម្ដេចតេជោនាយករដ្ឋមន្ត្រី | ជាទីប្រឹក្សា |

| | | | |
|---|---|---|---|
| ៨-ឯកឧត្តម | **ហ៊ឹម សុនិត្យា** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | ជាសមាជិក |
| ៩-លោក | **ប៉ុក បូរក្សេ** | ប្រធាននាយកដ្ឋានភាពយន្ត នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាសមាជិក |
| ១០-លោក | **អន សុភះ** | ជំនួយការឯកឧត្តម ម៉ៅ អាយុទ្ធ | ជាសមាជិក |
| ១១-លោក | **សុខ សំអាត** | ទីប្រឹក្សាក្រសួងទេសចរណ៍ | ជាសមាជិក |
| ១២-ឧ.ឯក | **រឿន ឧុទ្ធី** | ទីប្រឹក្សាសម្តេចតេជោនាយករដ្ឋមន្ត្រី | ជាសមាជិក |
| ១៣-ឧ.ឯក | **យ៉ាត ទូច** | សមាជិកក្រុមលេខាសម្តេចតេជោនាយករដ្ឋមន្ត្រី | ជាសមាជិក |
| ១៤-ឧ.ទោ | **អ៊ុន ស៊ីដារ៉ា** | មេបញ្ជាការកងពលតូចថ្មើរជើងលេខ២១ | ជាសមាជិក។ |

***គណៈកម្មការខាងលើនេះមានភារកិច្ចដូចខាងក្រោម៖**

- ផលិតភាពយន្តភាគរឿង **"កូនប្រុសក្រោមពន្លឺព្រះចន្ទពេញបូណ៌មី"** ឱ្យបានល្អត្រឹមត្រូវតាមសាច់រឿង ជាក់ស្តែងស្របតាមកាលៈទេសៈ និងដំណាក់កាលនីមួយៗប្រកបដោយគុណភាព។
- ទំនាក់ទំនងនិងសហការជាមួយអាជ្ញាធរពាក់ព័ន្ធ និងជំនាញទាំងអស់ ដើម្បីផលិតភាពយន្តភាគនេះ ឱ្យមានភាពល្អប្រសើរប្រកបដោយគុណតម្លៃ។
- អនុប្រធាន ទីប្រឹក្សា និងសមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការ។
- អនុប្រធាន និងសមាជិកគណៈកម្មការ ត្រូវជួយបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងជូនដល់ប្រធានគណៈកម្មការ លើការផលិតភាពយន្តភាគនេះ។
- ក្នុងករណីចាំបាច់ ទីប្រឹក្សាមានសិទ្ធិក្នុងការប្រឹក្សាយោបល់ជូនដល់គណៈកម្មការ ដើម្បីពិនិត្យ និងសម្រេចរាល់កិច្ចការ ដែលពាក់ព័ន្ធនឹងការផលិតភាពយន្តភាគនេះ។

**ប្រការ២.-**

បង្កើតអនុគណៈកម្មការមានដូចតទៅ៖

**ក. អនុគណៈកម្មការចាត់ការទូទៅ**

| | | | |
|---|---|---|---|
| ១-លោក | **អន សុភះ** | ជំនួយការឯកឧត្តម ម៉ៅ អាយុទ្ធ | ជាប្រធាន |
| ២-លោក | **ហួយ សុជាតិ** | ប្រធានការិយាល័យនៃនាយកដ្ឋានភាពយន្ត | ជាសមាជិក |
| ៣-លោក | **ឃិន ឧុត្តា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានភាពយន្ត | ជាសមាជិក |
| ៤-លោក | **រស់ តារម្យេ** | ជំនួយការលោក អន សុភះ | ជាសមាជិក។ |

*អនុគណៈកម្មការចាត់ការទូទៅមានភារកិច្ចចាត់ចែង និងសម្របសម្រួលរាល់តម្រូវការក្នុងការផលិតភាពយន្តភាគនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ខ. អនុគណៈកម្មការនិពន្ធ ដឹកនាំរឿង និងគ្រប់គ្រងតួសម្តែង**

| | | | |
|---|---|---|---|
| ១-លោក | **ហ៊ុយ វាសនា** | អ្នកនិពន្ធ និងដឹកនាំរឿង | ជាប្រធាន |
| ២-លោក | **ចាន់ រ៉ូណាន់** | | ជាអនុប្រធាន |
| ៣-លោក | **សេក ផល្លី** | | ជាសមាជិក |
| ៤-លោក | **មោក វាសនា** | | ជាសមាជិក។ |

*អនុគណៈកម្មការនិពន្ធ ដឹកនាំរឿង និងគ្រប់គ្រងតួសម្តែង មានភារកិច្ចស្រាវជ្រាវរៀបចំនិពន្ធ ដឹកនាំការសម្តែង និងគ្រប់គ្រងតួសម្តែងស្របតាមគោលការណ៍បច្ចេកទេស។

**គ. អនុគណៈកម្មការគ្រប់គ្រងសម្ភារផលិតរឿង**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **វ៉ាន់ ឆារស័ជួន** | ជំនួយការសម្តេចតេជោនាយករដ្ឋមន្ត្រី | ជាប្រធាន |
| ២-ឯកឧត្តម | **សៅ តិរុណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន | ជាអនុប្រធាន |

| | | | |
|---|---|---|---|
| ៣-លោក | **ម៉ុក មូរាឡ** | ប្រធាននាយកដ្ឋានភាពយន្តនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាសមាជិក។ |

*អនុគណៈកម្មការគ្រប់គ្រងសម្ភារផលិតរឿង មានភារកិច្ចផ្គត់ផ្គង់ គ្រប់គ្រង និងថែរក្សារាល់សម្ភារបច្ចេកទេសទាំងអស់ដែលបម្រើឱ្យការផលិតភាពយន្តភាគនេះ។

**ឃ.អនុគណៈកម្មការបច្ចេកទេសថត កាត់តដំឡើងរូបភាព និងសំឡេង**

| | | | |
|---|---|---|---|
| ១-លោក | **សុខ សំអាត** | ទីប្រឹក្សាក្រសួងទេសចរណ៍ | ជាប្រធាន |
| ២-លោក | **ជន គា** | ការីថត | ជាអនុប្រធាន |
| ៣-លោក | **ស៊ិន រតនៈ** | អនុប្រធានការិយាល័យនៃនាយកដ្ឋានភាពយន្ត | ជាសមាជិក |
| ៤-លោក | **ខែម សម្បត្តិ** | ជំការឯកឧត្តម ហ៊ឹម សុទិត្យា | ជាសមាជិក។ |

*អនុគណៈកម្មការបច្ចេកទេសថត កាត់តដំឡើងរូបភាព និងសំឡេង មានភារកិច្ចរៀបចំការថត កាត់តដំឡើងរូបភាព និងសំឡេង ហើយចងក្រងឱ្យទៅជាភាពយន្តសម្រេច។

**ង. អនុគណៈកម្មការ ហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ហ៊ឹម សុទិត្យា** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | ជាប្រធាន |
| ២-ឯកឧត្តម | **ជា ណារ៉េត** | អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ជាសមាជិក |
| ៣-លោក | **គួច ទារីថ្នា** | | ជាសមាជិក |
| ៤-លោក | **សយ សារ៉ាត់** | | ជាសមាជិក។ |

*អនុគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មានភារកិច្ចរៀបចំចាត់ចែង និងផ្គត់ផ្គង់រាល់ការចំណាយទាំងអស់ក្នុងការផលិតភាពយន្តភាគនេះ ចាប់ពីពេលរៀបចំផលិតរហូតត្រូវបានបញ្ចប់ជាស្ថាពរ។ រាល់ការចំណាយទាំងអស់ត្រូវមានការឯកភាពពីប្រធានគណៈកម្មការ។

**ប្រការ៣.-**

រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូនៈ**

- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អភិបាល រាជធានី-ខេត្ត
- ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន ខ.ភ.ម
- បញ្ជាការដ្ឋានកងទ័ពជើងគោក
- កងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ដូចប្រការ១ ប្រការ២ និងប្រការ៣
- ឯកសារ-កាលប្បវត្តិ